# ល្បិច
# និង
# គន្លឹះ
# ក្នុងការប្រើប្រាស់ PC

BY PROM SOKREACH

Published by the ANT Training Center

# អារម្ភកថា

គ្មាននរណាម្នាក់ដែលចេះគ្រប់យ៉ាងទេ តែក៏មិនគួរមិនចេះអ្វីសោះដែរ។ កាលពីខ្ញុំនៅពីតូច ខ្ញុំតែងតែជួបបញ្ហាកុំព្យូទ័រ ជាពិសេសពេលកំពុងលេងហ្គេម និងពេលដែលចង់ (Hack) ហ្គេម។ ខ្ញុំតែងតែបង្កបញ្ហាដល់បងប្រុសរបស់ខ្ញុំ ខណៈពេលដែលពួកយើងគ្មានកុំព្យូទ័រទំនើបៗ ហើយខ្ញុំក៏មិនចេះជួសជុលនិងដោះស្រាយបញ្ហាកុំព្យូទ័រនៅពេលខ្ញុំបង្កបញ្ហានោះទេ គឺគាត់តែងតែជាអ្នកដោះស្រាយជានិច្ច រហូតដល់ខ្ញុំបានចូលរៀននៅថ្នាក់បណ្តុះបណ្តាលបច្ចេកវិទ្យាអាន-ANT ទើបខ្ញុំអាចដោះស្រាយបញ្ហាជាច្រើនដោយខ្លួនឯងបាន តែដើម្បីពង្រឹងសម្ថតភាពបន្ថែម និងសម្រាយមន្ទិលសង្ស័យដែលខ្ញុំមានជាយូរណាស់មកហើយនោះ ខ្ញុំបានស្រាវជ្រាវបន្ថែមដើម្បីអភិវឌ្ឍន៍ខ្លួន តែដោយសារតែប្រធានបទដែលខ្ញុំបានស្រាវជ្រាវមួយចំនួនក៏ជាបញ្ហាចោទខ្លាំងនៅក្នុងសង្គម ទើបខ្ញុំសរសេរចំណុចទាំងនេះឡើងជាខេមរភាសាដើម្បីឲ្យ សាធុជនទាំងឡាយងាយស្រួលក្នុងការបឺតជញ្ជក់យកចំណេះដឹងនិងអភិវឌ្ឍន៍ខ្លួនបន្ថែម។

ជាចុងក្រោយខ្ញុំសូមជូនពរឲ្យអ្នកដែលបានអានកម្រងវណ្ណកម្មទាំងនេះឲ្យជួបតែភាពចម្រុងចម្រើននិងភាពជោគជ័យក្នុងជីវិត ហើយខ្ញុំសង្ឃឹមថាកម្រងវណ្ណកម្មនេះក៏ជាកម្លាំងចលករមួយក្នុងខ្សែជីវិតរបស់អ្នកដែរ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១៩

ព្រុំ សុខរាជ

<u>**មាតិកា**</u>


1. វិធីដោះស្រាយបញ្ហាមួយចំនួនតាម Command Prompt
2. Shortcut Key Hack
3. របៀបមើលវីដេអូ 3D លើកុំព្យូទ័រ
4. របៀបធ្វើ Bios update
5. របៀបរក Crack និង Serial សម្រាប់ Program នានា

1. <u>វិធីដោះស្រាយបញ្ហាមួយចំនួនតាម Command Prompt</u>

❖ Hard Disk

បើសិនជាអ្នកមានបញ្ហា Hard Disk ដើរយឺត ហើយមិនដឹងថាត្រូវជួសជុលយ៉ាងម៉េច។ សូមសាកល្បងធ្វើតាមរបៀបនេះជាការសង្គ្រោះបឋមដោយ៖

i) Run command promptជាadministration

ii) Type: chkdsk c: /f /r

Drive ដែលយើងចង់ជួសជុលនិង recover file — ឲ្យជួសជុល (Fix) — ឲ្យ recover file ដែលខូច ឬ បាត់សូម្បីតែ External Drive ឬ USB Flash Drive

iii) វានិងសួរថា Would you like to schedule this volume to be checked the next time system restarts? (Y/N)




iv) Type Y

v) Restart កុំព្យូទ័ររបស់អ្នក

\+ យើងត្រូវចាំមួយសន្ទុះធំ ហើយកុំភ្លេចសាកថ្មឲ្យពេញផងមុនប្រើវិធីដើម្បីធ្វើឲ្យប្រាកដថាវាដំណើរការបានពេញ (100%)

❖ USB Flash Drive ឬ External Hard Drive

ពេលដែលមេរោគចូល Flash ឬ External Hard Drive របស់យើង ចំេពោះករណីមួយចំនួន មេរោគនោះនិងធ្វើឲ្យ file ក្នុង Flash ឬ External Hard Driveក្លាយ

ជា shortcut file ទាំងអស់ តែយើងអាចទាញ file ដ៏មានតម្លៃរបស់យើងមកវិញបាន ដោយប្រើ system របស់យើងដោយប្រើ command prompt ដោយ៖

i) Run command promptជាadministration

ii) Type: attrib -h -r -s /s /d e:*.*

Clears hidden file attribute   Clears read-only file attribute   Clears system file attribute

Processes file in all directories in the specified path   Process folder as well   Drive that you want to recover file

iii) ចូលមើល Flash ឬ External Hard Driveរបស់យើង

iv) Copy file ដ៏មានតម្លៃរបស់យើង ចេញពី Flash ឬ External Hard Drive ជាការស្រេច

## 2. Shortcut Key Hack

ពេលដែលប្រើប្រាស់កុំព្យូទ័រ ជាពិសេសពេលដែលកំពុងចុច keyboard អ្វីដែលធុញទ្រាន់ជាងគេ គឺនៅពេលដែលដៃយើងនៅជាប់និង keyboard តែត្រូវយកដៃចេញ ដើម្បីប្រើ mouse បញ្ជា។ វាហាក់ដូចជាខាតពេលណាស់ ហើយក៏ដូចជាមិនទាន់ចិត្តសោះសម្រាប់មនុស្សមួយចំនួន។ ខាងក្រោមនេះជា Shortcut Key មួយចំនួនដែលអាចសម្រួលដល់ការប្រើប្រាស់ និង កាត់បន្ថយកំហាតពេលមួយចំនួន៖

i) ចុច + D ដើម្បី show desktop ពិសេសនៅពេលដែលកុំព្យូទ័រយើងគាំងចុចអ្វីលែងបាន

ii) Ctrl + Backspace ដើម្បីលុបម្តងមួយពាក្យ ឬ មួយកថាខណ្ឌ(បើសិនជាចុចជាប់) ហើយអាចប្រើវាបានគ្រប់ទីកន្លែងទាំងអស់

iii) F2 ដើម្បី rename file ឬ folder (មិនដំណើរការសម្រាប់ប្រភេទកុំព្យូទ័រមួយចំនួន)

iv) ចុច + I ដើម្បីបើក Setting

v) ចុច + A ដើម្បីបើក Action Panel




Action Panel

vi) ចុច ⊞ + + (សញ្ញាបូក) ឬ - (សញ្ញាដក)ដើម្បីពង្រីក ឬ បង្រួម screen នៅពេលដែល
យើងចង់មើលអ្វីមួយឲ្យលម្អិត ឬ ងាយស្រួលមើលជាងមុន




vii) ចុច ⊞ + លេខ ដើម្បីបើកកម្មវិធីដែលដាក់នៅលើ task bar ដោយរាប់ពីឆ្វេងទៅស្តាំ
ឧ. ⊞ + 4 នោះវានិងបើកកម្មវិធីទី4ដែលយើងដាក់នៅលើ task bar ដោយរាប់ពីឆ្វេង
ទៅស្តាំដូចយើងចុច mouse អញ្ចឹងដែរ

viii)ចុច + S ដើម្បីបើក search bar search button លើ task bar




Search bar

3. <u>របៀបមើលវីដេអូ 3D លើកុំព្យូទ័រ</u>

យើងត្រូវមាន៖

1.វ៉ែនតា3D






2.ដំឡើងកម្មវិធី KM Player

3. វីដេអូ3D (ពេលបើកមកដំបូងវីដេអូដំណើរការពីរផ្ទាំងទន្ទឹមគ្នា)។

- របៀបធ្វើឲ្យ KM Player បង្ហាញរូប3D៖

  1. បើក KM Player
  2. Right Click on KM Player ➔ Select 3D Controls ➔ Select Side by Side ➔ 2D
  3. ពាក់វ៉ែនតា 3D
  4. ទាញវីដេអូដែលយើងចង់មើលចូលក្នុង KM Player ។

+ <u>**បញ្ជាក់**</u> ៖ **បើសិនជាវ៉ែនតា3Dរបស់យើងម្ខាងពណ៌ខៀវ ម្ខាងពណ៌ក្រហម យើងត្រូវ Selectយក Red/Blue-True (អាស្រ័យទៅតាមពណ៌ម្ខាងៗនៃវ៉ែនតា3D) ។**

4. <u>របៀបធ្វើ Bios update</u>

បើសិនជាកុំព្យូទ័ររបស់អ្នកដំណើរការដោយគ្មានបញ្ហាអ្វី ហើយ device ទាំងអស់ដែលភ្ជាប់ជាមួយកុំព្យូទ័រគឺ bug free នោះគឺគ្មានមូលហេតុអ្វីត្រូវឲ្យ update bios ទេ តែបើសិនជា computer អ្នកចាស់ និងមិនអាចភ្ជាប់ទៅ device មួយចំនួននោះគឺត្រូវ update bios ហើយ។ ដើម្បី update bios យើងត្រូវ៖

i) មើលsystem modelកុំព្យូទ័រដោយសរសេរmsinfo32លើRun

ii) វានិងបង្ហាញsystem information

iii) យើងត្រូវត្រួតពិនិត្យលើsystem model



iv) Search system model + bios update on Google




v) ចូល website brand កុំព្យូទ័រហើយ download file នោះ

vi) បិទ program ផ្សេងៗ ហើយបើក file ដែលបាន download នោះ

vii) យកពាក្យ OK ហើយ OK ទៀត

viii) វានិងបង្ហាញផ្ទាំងមួយបញ្ជាក់ថា វាកំពុងចេញប្រតិបត្តិការ



6. របៀបរក Crack និង Serial សម្រាប់ Program នានា

5. របៀបរក Crack និង Serial សម្រាប់ Program នានា

កម្មវិធីភាគច្រើនសុទ្ធតែត្រូវការ Serial Number ដើម្បី Activate។ បើគ្មាន Crack និង Serial ទេ យើងនិងអាចប្រើ Program នោះក្នុងរយៈពេលខ្លី ឬ បំពេញមុខងារមិនបានពេញលេញ ពិសេស Program ប្រភេទ Anti-Virus។ ខាងក្រោមនេះជាវិធីសាស្រ្ត និង គន្លឹះមួយចំនួនដើម្បីរក Crack និង Serial៖

-សុំ Copy Folder File Set Up ពីអ្នកដែលអាចជួយបាន (មិត្តភក្តិ, គ្រូបង្រៀន, បងប្អូន...)

-ចូល download file set up ពី website មួយចំនួនដូចជា igetintopc.com, thepiratebay.org, p2push.net... ដែលមានភ្ជាប់ Crack ឬ Keygen program ឬ Serial សរសេរទុកស្រាប់ក្នុង Notepad នៅពេល Download មក តែត្រូវធ្វើឲ្យប្រាកដថា File ដែល Download យកមកមានសុវត្ថិភាព 100% ចៀសវាងការនាំមេរោគចូលកុំព្យូទ័រ។




igetintopc.com




P2Push.net




Thepiratebay.org

+ <u>បញ្ជាក់</u> ៖ ចំពោះ Thepiratebay.org ត្រូវប្រើជាមួយកម្មវិធី **uTorrent** ហើយ **កត់សម្គាល់ផងដែរថា Thepiratebay.to ជា Website ក្លែងបន្លំទេ។**

- ប្រើប្រាស់ Website ដើម្បី Generate serial តាម Online ដូចជា keygenninja.com ឬ serials.ws ដែលជា Website មិនចម្លងមេរោគដល់កុំព្យូទ័រទេ




Serials.ws




KeyGenNinja.com